54كمبودي بالخميرية:
ព្រះរាជាណាចក្រ
(កម្ពុជា

# هيثم بن محمد سرحان

MahadSunnah

و لا تعتدوا.
ហើយចូរពួកអ្នកកុំបំពាន
ឱ្យសោះ

و لا تعثوا في الأرض مفسدين.
ហើយចូរពួកអ្នកកុំបំពាននៅលើ
ផែនដីដោយបង្ករវិនាសកម្ម
ឱ្យសោះ

و لا تلبسوا الحق بالباطل
ហើយចូរពួកអ្នកកុំលាយឡំ
ប្រការពិតជាមួយនិងប្រការមិន
ពិត

و لا تقف ما ليس لك به علم
ហើយចូរអ្នកកុំនិយាយនូវអ្វីដែលអ្នក
មិនបានដឹង

و لا تمش في الأرض مرحا
ហើយចូរអ្នកកុំដើរនៅលើផែនដី
ដោយភាពក្រអឺតក្រទមឱ្យសោះ

و لا تصعر خدك للناس
ហើយចូរអ្នកកុំងាកមុខចេញពី
មនុស្សលោកដោយអំនួត

و اخفض جناحك للمؤمنين.
ហើយចូរអ្នកលំទោនកាយរបស់អ្នក
ចំពោះអ្នកដែលមានជំនឿចុះ

و اغضض من صوتك
ហើយចូរអ្នកបន្ទន់សំឡេង
របស់អ្នក

و اقصد في مشيك.
ហើយចូរអ្នកបន្ទន់ឥរិយាបថ
ក្នុងដំណើររបស់អ្នក

و اعرض عن الجاهلين.
ហើយចូរអ្នកជៀសវាងពីទង្វើរបស់
ពួកល្ងង់ខ្លៅ

خذ العفو و أمر بالعرف.
ចូរអ្នកទទួលយកការអធ្យាស្រ័យ
និងប្រើគ្នាឱ្យធ្វើល្អ

ادفع بالتي هي أحسن.
ចូរអ្នកតបតវិញចុះនូវអ្វីដែលល្អ
បំផុត

ادع إلى سبيل ربك بالحكمة
ចូរអ្នកអំពាវនាវមនុស្សលោកទៅកាន់
មាគ៌ានៃម្ចាស់របស់អ្នកដោយគតិបណ្ឌិត

لا تبطلوا صدقاتكم بالمن و الأذى
ចូរពួកអ្នកកុំបំផ្លាញផលបុណ្យនៃការបរិ
ច្ចាកដោយការរំលើកនិងបញ្ឈឺចិត្ត

و لا تأكلوا أموالكم بينكم بالباطل
ហើយចូរពួកអ្នកកុំស៊ីទ្រព្យសម្បត្តិ
គ្នាដោយខុសច្បាប់

و لا تنابزوا بالألقاب.
ហើយចូរពួកអ្នកកុំដាក់ងារមិនល្អ
ឱ្យសោះ

لا يسخر قوم من قوم
ហើយចូរកុំឱ្យក្រុមមួយមើលងាយ
ក្រុមមួយទៀតឱ្យសោះ

و لا يغتب بعضكم بعضا
ហើយចូរអ្នកកុំនិយាយដើមគ្នា
ឱ្យសោះ

و لا تجسسوا.
ហើយចូរពួកអ្នកកុំសើ
បការ

إجتنبوا كثيرا من الظن
ចូរពួកអ្នកជៀសវាងឱ្យឆ្ងាយពី
ប្រការសង្ស័យគ្នា

ادخلوا في السلم كافة
ចូរពួកអ្នកចូលសាសនាឥស្លាម
ដោយពិតប្រាកដ

و إذا حييتم بتحية فحيوا بأحسن منها
ហើយនៅពេលដែលពួកអ្នកត្រូវបាន
គេស្វាគមន៍ចូរពួកអ្នកស្វាគមន៍វិញ
ដោយប្រសើរជាងនេះ

و بالوالدين إحسانا و ذي القربى و اليتامى
ហើយត្រូវធ្វើល្អចំពោះឪពុកម្ដាយញាតិស
ន្ដាននិងក្មេងកំព្រា

و أطعموا البائس الفقير
ហើយចូរពួកអ្នកបរិច្ចាកឱ្យអ្នក
ក្រីក្រ

و لا تتبدلوا الخبيث بالطيب
ហើយចូរពួកអ្នកកុំប្ដូររបស់ដែលអាក្រក់
ដោយរបស់ដែលល្អ

و آتوا اليتامى أموالهم
ហើយចូរពួកអ្នកប្រគល់ឱ្យកូនកំ
ព្រាទាំងនោះនៅទ្រព្យសម្បត្តិរបស់
ពួកគេ

أنفقوا مما رزقناكم
ចូរពួកអ្នកបរិច្ចាកមួយចំនួនអំពីអ្វី
ដែលយើងបានប្រទានឱ្យពួកអ្នក

و قولوا قولا سديدا
ហើយចូរពួកអ្នកពោលពាក្យសំដីណា
ដែលល្អត្រឹមត្រូវ

و قولوا للناس حسنا
ហើយចូរពួកអ្នកនិយាយស្ដីល្អៗ
ជាមួយមនុស្សលោក

و لا تعاونوا على الإثم و العدوان
ហើយចូរពួកអ្នកកុំជួយគ្នាធ្វើអំពើបាប
និងធ្វើជាសត្រូវនិងគ្នាឱ្យសោះ

و تعاونوا على البر و التقوى
ហើយចូរពួកអ្នកជួយគ្នាក្នុងការធ្វើអំពើល្អ
និងកោតខ្លាចអល់ឡោះ

و احفظوا أيمانكم
ចូរពួកអ្នកការពារសម្បថរបស់ពួក
អ្នក

و أوفوا بعهد الله إذا عاهدتم
ហើយចូរពួកអ្នកគោរពកិច្ចសន្យា
របស់អល់ឡោះនៅពេលដែលពួកអ្នក
បានសន្យាហើយនោះ

و أوفوا الكيل إذا كلتم
ហើយចូរពួកអ្នកបំពេញរង្វាស់រង្វាល់
នៅពេលណាពួកអ្នកវាស់ឬវាល់នោះ

و زنوا بالقسطاس المستقيم
ហើយចូរពួកអ្នកថ្លឹងនិងជញ្ជីង
ដែលត្រឹមត្រូវ

كونوا قوامين بالقسط
ចូរពួកអ្នកប្រកាន់ឱ្យបានខ្ជាប់ខ្ជួនខ្ជួននូវ
ភាពយុត្តិធម៌

اعدلوا
ចូរពួកអ្នកប្រកាន់នូវភាព
យុត្តិធម៌